# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យឆ្លងព្រះវិហារសន្តយ៉ូសែបពោធិ៍ធំ
# ថ្ងៃទី០៦ កុម្ភៈ ២០១៧

អត្ថបទទី១៖ កណ ១,១-១៩
ដំណឹងល្អ៖ មក ៦,៥៣-៥៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងនឹកឃើញដល់មរណសាក្សីនៃប្រទេសជប៉ុន នឹកឃើញដល់សម្ដេចប៉ាបដែលបាននិយាយដល់លោកអភិបាលឡាវ-កម្ពុជា ជាព្រះសហគមន៍តូចតាចដែលតស៊ូ ដែលមានទុក្ខលំបាកច្រើន ប៉ុន្តែជាព្រះសហគមន៍ដែលណែនាំឲ្យព្រះសហគមន៍សកលមានកម្លាំង។ យើងនឹកឃើញដល់មរណសាក្សីនៅប្រទេសជប៉ុន មរណសាក្សីនៅប្រទេសកម្ពុជា ដោយដឹងថាឈាមរបស់គ្រីស្តបរិស័ទ ឈាមរបស់មរណសាក្សីជាពូជដែលណែនាំឲ្យព្រះសហគមន៍លូតលាស់បាន។ ក្នុងអត្ថបទតីមួយ "**ព្រះជាម្ចាស់ដែលបង្កើតពិភពលោក ដេលបានបង្កើតផ្ទៃមេឃនិងផែនដី ព្រះជាម្ចាស់ដែលបង្កើតពូជនិងធម្មជាតិទាំងឡាយ**" ពេលយើងដើរក្នុងប្រទេសជប៉ុនប៉ុន្មានថ្ងៃកន្លងមក យើងបានដើញធម្មជាតិស្អាតណាស់ ដោយសារនេះជាព្រះហស្តរបស់ព្រះជាម្ចាស់ពិតមែន ដែលបានបង្កើតអ្វីៗទាំងអស់។ ដោយសារ ជំនឿរបស់គ្រីស្តបរិស័ទយើងដឹងថាជីវិតរបស់យើងអាចទៅមុខបាន ជំនឿរបស់យើងអាចរកកម្លាំងនៅក្នុងមរណសាក្សី។ ទីនេះជាកន្លែងដែលមរណសាក្សីនៅប្រទេសជប៉ុនបានចេញធ្វើដំណើរ១០០០គីឡូម៉ែត្រ នៅតាមទីក្រុងនីមួយៗដែលមានអ្នករំខានគេបៀតបៀនគេ មើលងាយគេ រហូតដល់ទីក្រុងណាហ្គាសាគីទើបគេសម្លាប់។ នៅពេលនេះយើងនឹកឃើញនិងចូលរួមក្នុងជីវិតមរណសាក្សីជប៉ុន នឹកឃើញដល់អំណរសប្បាយដែលយើងមាននៅក្នុងជីវិតរបស់យើង មិនសូវមានការបៀតបៀន មិនសូវមានការមើលងាយដោយសារជំនឿរបស់យើង។ ដូច្នេះសូមឲ្យជំនឿរបស់យើងរឹងមាំ នៅក្នុងសង្គមដែលរីកចម្រើនលឿន សូមឲ្យពន្លឺរបស់ព្រះគ្រីស្តតាមរយៈសក្ខីភាពរបស់យើង ដើម្បីទៅជាពន្លឺនិងអំបិលរបស់មនុស្សទាំងឡាយ។ សូមព្រះអង្គជួយយើងឲ្យយើងអាចលីឈើឆ្កាងតទៅទៀត ដើម្បីបង្កើតព្រះសហគមន៍ដែឡជាព្រះសហគមន៍របស់ព្រះគ្រីស្ត។ អាម៉ែន។